**សកម្មភាព** ៖ **ល្បែងការងារទាំងអស់សុទ្ធតែសំខាន់**

**វិទ្យាសាស្ត្រ**

បំណិនអនាម័យ (ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម)

**សិក្សាសង្គម**

បំណិនសង្គម (ការយល់ដឹងពីបរិស្ថាន និងវិធីការពារ)

**គោលបំណង**

**(វិទ្យាសាស្ត្រ)** ប្រាប់ពីទីកន្លែងទុកដាក់សម្រាមតាមកាលកំណត់។

**(សិក្សាសង្គម)** ប្រាប់ឈ្មោះការងារ ឬ ទីកន្លែងដែលទាក់ទងនឹងបរិស្ថានធម្មជាតិ និងទង្វើការពារបរិស្ថាន ដូចជាមិនចោលសំរាមពាសវាលពាសកាល វិធីទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ប្រអប់ ធុងសម្រាម ការ៉ុង បាវ ថង់ ឬ កេះសម្រាប់ប្រមូលសម្រាម។

**ការរៀបចំ** ៖ ស្វែងយល់ពីការចោលសម្រាមនៅកម្ពុជា

**សេក្តីណែនាំ៖**

1. សួរក្មេងៗទាំងអស់ថា៖ តើការងារមួយណាដែលពួកគេគិតថាជាការងារសំខាន់?
2. ពិភាក្សា៖ តើហេតុអ្វីបានជាការងារទាំងនោះមានសារៈសំខាន់បែបនេះ?
3. ប្រាប់ក្មេងៗថា៖ ថ្ងៃនេះអ្នកគ្រូមានការងារមួយដែលចង់សួរកូនៗ។
4. សួរពួកក្មេងៗ៖ តើការងារប្រមូលសម្រាមជាការងារមានសារៈសំខាន់ដែរឬទេ?
   តើហេតុអ្វីបានជាកូនៗគិតថាការរើសសម្រាមមានសារៈសំខាន់?
   តើនៅតាមដងផ្លូវទៅជាយ៉ាងណាដែរ?
   តើមានសុខភាពល្អដែរទេ?
5. (ប្រសិនបើក្មេងឆ្លើយថាការរើសសម្រាមសំខាន់ មិនបាច់សួរសំណួរទី៥ទេ)
   ប្រសិនបើក្មេងៗគិតថាការងាររើសសម្រាមមិនមានសារៈសំខាន់។
   តើហេតុអ្វីបានជាកូនៗគិតថាការរើសសម្រាមមិនមានសារៈសំខាន់?
   តើនៅតាមដងផ្លូវទៅជាយ៉ាងណាដែរ?
   តើមានសុខភាពល្អដែរទេ?

6. ប្រាប់ក្មេងៗថានេះគឺជាមេរៀនដែលពួកគេទាំងអស់ត្រូវធ្វើជាអ្នកប្រមូលសម្រាមនៅក្នុងថ្ងៃនេះ។
7. នាំក្មេងៗទាំងអស់ដើរជុំវិញទីធ្លាសាលា និងប្រាប់ឱ្យពួកគេប្រមូល ឬ រើសសម្រាមទាំងអស់តាមដែលអាចធ្វើទៅបាន។ រើសដាក់ក្នុងប្រអប់ ថង់ ការុង បាវ ឬ ធុងសម្រាមជាដើម។
8. ប្រាប់ក្មេងៗត្រូវទុកដាក់ធុងសម្រាម ឬ ប្រអប់នៅកន្លែងដែលសាកសមងាយស្រួលដាក់សម្រាម។
9. ចូលទៅក្នុងបន្ទប់រៀនវិញ និងប្រាប់២ចំណុចទៅពួកគេថា
    - នេះហើយជាហេតុផលដែលអ្នកទាំងអស់គ្នាត្រូវចោលសម្រាមឱ្យបានត្រឹមត្រូវ ជៀសវាងបោះចោលពាសវាលពាសកាល ដោយគ្មានសណ្តាប់ធ្នាប់ ។
    - គ្រប់ការងារទាំងអស់សុទ្ធតែមានប្រយោជន៍ និងមានសារៈសំខាន់